« Dol-Ek »

30-12-52



INDOCHINE FRANÇAISE
RÉGIE DU DÉPÔT LÉGAL

437
134

សំណាងដែលសាងបងបានករ　　រាសីគិនរមកពីព្រេង ។
ខ្ញុំសូមរំលឹកនឹកដល់គុណ　　មាតាបិតាខ្ញុំនេះឯង
ខ្ញុំបានបៀមបៅដោះពីក្មេង　　គុណអ្នកជាក់ស្ដែងជួយខ្ញុំផង ។
ឥឡូវនេះកូនមានទុក្ខធំ　　សត្រូវមកបំខ្ញុំជាម្ដង
សូមជួយឲ្យបានដូចបំណង　　សេចក្ដីប៉ុនប៉ងប្រាថ្នានេះ ។
សច្ចារួចស្រេចស្ដេចត្រាស់ថា　　នៃពួកសេនាបើដូច្នេះ
យើងគិតសង្គ្រាមក្នុងគ្រានេះ　　កុំឲ្យវេរវេះគិតឲ្យឆាប់ ។
មេទ័ពចេញពប់កូនទាហ៊ាន　　ការហាត់ប្រឹតប្រៀនទុកសម្រាប់
មេទ័ពថាយើងគ្រប់គ្នាស្ដាប់　　ថាបើយើងស្លាប់ក្នុងសង្គ្រាម ។
ហៅពេញស្រឡាញ់ដល់ផែនដី　　នឹងម្ចាស់សិរសើស្ដិ៍បរណាម
តាំងចិត្តតែមួយកុំទីមទាម　　នេះហើយយកឈាមក្រាលផែនដី ។
ទើបស្ដេចយាងចេញពីនគរ　　សេមាបវរប្រញាប់ខ្ញី
សេនាមាត្យហ្មឺនមុខមន្ត្រី　　ដល់ចុងបុរីបញ្ឈប់ពល ។
ទើបឲ្យសង់ព្រះពន្លាជ័យ　　រោងរ៉ៃរោងខ្ទុំដោយខ្លាយខ្ទល់
ប្រដាប់សម្រាប់ឲ្យពួកពល　　ប្រយោជន៍តទល់នឹងសត្រូវ ។
ស្ដេចទ្រង់ឲ្យលើកទង់ជ័យឡើង　　ដំកើងនៅមុខពន្លាកូវ
ឲ្យដឹងដល់ពួកខ្មាំងសត្រូវ　　ទ័ពនៅខាងនាយឃើញប្រាកដ ។
អនុសេនីយ៍ទោ-សេនីយឯក　　ឲ្យពួកទ័ពស្រែកឡើងជាបទ

នគររាជដោយពាក្យហ្មត់ចត់ បួនសួនប្រាកដទេវតាថ្មី ៗ

## បទនគររាជ

សូមពួកទេ–ព្តា រក់–សាមហា–ក្សត្រយើង ឲ្យបានរុងរឿង ដោយជ័យម–ង្គលស្រីសួ–ស្តី យើងខ្ញុំព្រះអង្គ សូមជ្រកក្រោមម្លប់- ព្រះបា–រ–មី នៃព្រះន–របតីវង្សក្ស–ត្រាដែលសាងប្រា–សាទល្អ គ្រប់គ្រងសាកេតបុរីថ្កើងថ្កាន ៗ ចប់បទនគររាជតែប៉ុណ្ណោះ ៗ

## បទពាក្យប្រាំពីរតទៅ

ពួកទ័ពគំនាប់ដល់ទង់ជ័យ ថ្វាយព្រះពរថ្វៃមហាក្សត្រក្រន្ត
បួនសួនទេវតានៅគ្រប់ស្ថាន សូមប្រកបមានជ័យបេស្តា ៗ
ស្តេចទ្រង់បង្គាប់ពួកអាឡាក់ ជានៃចូលអ្នកតែងរាជសាស្ន៍
ក្រាបទូលព្រះបាទអង្គឯកា ថាយើងអនុជាមកដល់ហើយ ៗ
ឲ្យប្រុងឲ្យរៈប្រៀបរៀបរេហ៍ពល កុំឲ្យបង្អែបង្អង់ឡើយ
យើងប្រយុទ្ធគ្នាថ្ងៃនឹងហើយ យើងប្រាប់បានឲ្យដឹងសេចក្តី ៗ
រាជទូតនាំសារ៍ថ្វាយប្រញាប់ ឯអង្គឯកាព្រះចក្រី
ស្តេចទតអស់អាថ៌សារសេចក្តី ប្រាប់រាជទូតខ្ញុំឲ្យវិលវិញ ៗ
ក្សត្រិយ៍ទាំងពីររៀបពលស្រេច តែមួយរំពេចឥតទុក្ខមេញ
តាំងភ្លើងគ្រប់ដៃប្រុងប្រៀបបាញ់ ពួកពលខ្វល់ខ្វាញ់ប្រឹងទ្រៀបត្រា ៗ

ស័ព្ទសូរកាំភ្លើងពួកក្រើក ស្មើនឹងរបើកព្រៃព្រឹក្សា
ញាប់ញ័រគិរីទីបព្វតា គួរឲ្យអស្ចារ្យកពផែនដី ៗ
ពលសេះគោគោកគជា ដេញគ្នាឥតមានត្រាប្រណី
ខ្លះធ្លាក់ពីលើខ្នងដំរី ខ្លះឯបនឹងព្រៃចាំស្កាត់ពល ៗ
ផឹតអ័ព្ទអស់ចាំងមេឃា ពួកពលមើលគ្នាស្ទើពុំយល់
ផ្សែងសព្វទិសាទីមណ្ឌល ស្លាប់នាយស្លាប់ពលពេញត្រៀបត្រា ៗ
ព្រះបាទឯកាពាភណាសី ពលស្លាប់ច្រើនក្រៃពេកមហិមា
ទៀងគង់លើខ្នងអស្សពាហ៍ យកកន្សែងណាបក់ពលខ្មី ៗ
ទើបកើតជាពលច្រើនអនេក គួរអស្ចារ្យប្លែកក្នុងលោកិយ
បក់ចាំងកាំភ្លើងច្រើនក្រាសក្រៃ ឲ្យកាន់គ្រប់ដៃឥតគណនា ៗ
គួរស្ញែងគួរខ្លាចឫទ្ធិបារមី អង្គព្រះនរបតីមានបេស្កា
ដេញពលឲ្យចូលតយុទ្ធនា ពលប្រឡូកគ្នាឥតញញើត ៗ
ព្រោះអាងដំរេះបេះធ្វើពល រយពាន់ហ៊ីនសែនបក់បោយកើត
ស្លាប់គរលេលកែលបក់ឡើងព្រីត កើតបានជាពលពេញដវែល ៗ
ព្រះបាទសាកេតអនុជា ឃើញពលយោធាគេក្រាសក្រៃល
គ្រវែងខ្សែទៅចងវណោល ពលក្រៃលដូចក្រងចងគ្រៀកនៅ ៗ
ដំបងវាយឯងស្លាប់គ្មានសល់ អស់ចាំងរេហ៍ពលចិត្តឃោរឃៅ
ឯអង្គព្រះបាទឯកានៅ មិនត្រូវដំបងចងពុំបាន ៗ

ឯកាគង់លើខ្នងអស្សពាហ៍ បក់បោយយោធាឥតរវាន
ពួកពលដែលស្លាប់ទាំងប៉ុន្មាន កើតបានគ្មានសល់ពលទាំងអស់ៗ
បត់គ្រឿងសាស្ត្រាវុធគ្រប់ដៃ កាំភ្លើងដាវដ័យគ្មានបន្ទោះ
គ្រប់នាយកយពលកាល់មិនខ្ចស់ ឥតមានខ្មាបសោះព្រោះចម្បាំងៗ
ស្តេចឲ្យលើកពលបលទៅគ្រឹក សន្ធឹកដូចព្យុះសង្គ្រាមខ្លាំង
ប្រឡូកប្រឡាក់កាប់ចាក់ខ្លាំង ប្រណាំងប្រជែងដាវវែងខ្លី ៗ
ខ្លះកាប់ផ្តាច់ពាក់កណ្តាលខ្លួន ដួលផ្ទួនទៅផ្កាប់ផ្ងាប់ទីដី
ឈាមហូរចេញខ្ចាយពីកាយខ្មី ពាសពេញផែនដីរាប់មិនអស់ ៗ
ព្រះបាទឯកាពារាណសី ពលស្លាប់ច្រើនក្រៃបង់អាប់យស
ត្រាន់ព្រះហឫទ័យពលរលោះ ស្លាប់អស់ស្ទើរដល់បរាជ័យ ៗ
ចូលចាប់ឯកាពារាណសី ដើម្បីនឹងយកមកបំណុះ
អនុសេនីយ៍ត្រីស័ក្តិ ១ ទូលថាកុំព្រួយបង្គំបុះ ៗ
ព្រះបាទឯកាពារាណសីនុ៎ះ សូមព្រះទ្រង់យសទុកឲ្យខ្ញុំ
អនុសេនីយ៍ទោតីស័ក្តិ ២ ទូលព្រះភូមិបពិត្រកុំ ៗ
ព្រួយព្រះហឫទ័យនៃបរម ទ្រង់ទុកឲ្យខ្ញុំចូលទៅចាប់
អនុសេនីយ៍ឯកប៉ុកស័ក្តិ ៣ ទូលព្រះបក្រីសូមទ្រង់ប្រាប ៗ
ព្រះបាទពារាណសីអនុអត្តភាព បង់លាភខ្ចូបការអន្ទ្យរដល់
វរសេនីយ៍ត្រីស័ក្តិ ៤ បង្គំផ្ទាល់ខ្លួនព្រះទសពល ៗ

ទូលថាឯកាស្តេចកំហល អាងបេះបក់ពលបក្សិនមិនគិត ៗ
វរសេនីយ៍ទោគឺស័ក្តិ៥ ទូលតាមចំណាំព្រះទ្រង់បុត្រ
លើកហត្ថអញ្ជលីទាំងទូពិត សូមព្រះភូមិន្ទទ្រង់គិតសិន ៗ
ព្របាទឯកាពារាណសី ឡើងសោយរាជ្យថ្មីជាភូមិន្ទ
មានកន្សែងបោយទឹងនាំងផ្អិន ជារៀមព្រះនរិន្ទទិពសទៅ ៗ
ហេតុនេះសូមទ្រង់ព្រះសណ្តាប់ កុំចាប់ទោសាខ្ញុំព្រះចៅ
សេចក្តីទូលទាស់ទោះខុសត្រូវ ពិតតាមតម្រូវតម្រាស់មក ៗ
ឮថាព្រះអង្គពាត់ព្រះរៀម បែកបាក់ទាក់ទាមត្រាប់ប្រៀតជ្រក
កន្ទះព្រៃព្រឹក្សាខំរត់រក កាលទ្រង់យាងមកពីស្រុកយក្ស ៗ
អនុជាសរនាការៈស័ព្ទ ទ្រង់ព្រះសណ្តាប់តាមធុរៈ
នឹកឃើញកាលចេញពីស្រុកយក្ស ពីរនាក់រៀមបងបែកបាក់ទៅ ៗ
ទើបស្តេចមានព្រះបន្ទូលថ្មី វរៈសេនីយ៍ទោនោះកូវ
ថាលោកស័ក្តិ៥ ជាបែបត្រូវ ដូច្នេះយើងនៅបន្អង់សិន ៗ
ព្រះបាទឯកាពារាណសី ដម្មោះទង់ជ័យព្រះទ័យជិន
គង់សេះបូលបមអង្គព្រះនរិន្ទ សាកេតភូមិន្ទអនុជា ៗ
បូលផិតយាងចុះចាកខ្នងសេះ តម្រេះស្តេចសួរសាកសាវតារ
វេស្រប់ផម្បង់កាយឯណា ក្សត្រាបានមកពីស្រុកអ្វី ៗ
សូមមានបន្ទូលឲ្យខ្ញុំដឹង សារស័ព្ទតម្ណឹងសព្វសេចក្តី

ចូរស្តេចកុំលាក់ទឹនខ្ញុំ ខ្ញុំមានសង្ស័យក្នុងចិត្តណាស់ ៗ
អនុជាសាកេតបុរីរម្យ ពុងគាសុំបញ្ជាក់ច្បាស់
សាវតារអនុជាសាកេតណាស់ ចង់ច្បាស់ខ្សែបង់ជម្ងឺភ័យ ៗ
អនុជាមានព្រះបន្ទូលប្រាប់ តាមដោយសារស័ព្ទពាក្យអតិប្រាយ
រីឯខ្សែបង់ជម្ងឺភ័យ បានមកពីឆ្ងាយគឺស្រុកយក្ស ៗ
ព្រះបាទឯកាពាកណាសី អនុជាស្តីប្រាប់ស្តាប់បានជាក់
ខ្សែបង់ជម្ងឺបានពីយក្ស ស្តេចភ្ញាក់ហឫទ័យស្តីពុំរួច ៗ
ទើបដួលព្រះកាយដល់ពសុធា ហត្ថាបាទាញ័រត្រីព្រួច
ពុថាស្រុកយក្សស្តេចកាន់កួច គំនិតគែគិតគួយូរហើយ ៗ
ឯអគ្គព្រះបាទអនុជា ឃើញព្រះជេដ្ឋាដួលកែសកើយ
ដឹងដាក់ព្រះរៀមស្តេចច្បាស់ហើយ ទ្រង់កន្ទ្រង់សោយសោកសន្ធប់ ៗ
អមាត្យមន្ត្រីប័ត្រកន ក្សត្រតាំងពីរធង់ដោយគោរព
ទើបឲ្យដងទឹកយកមកស្រប់ ស្វាងពីសន្ធប់ដឹងព្រះកាយ ៗ
ព្រះបាទឯកាពាកណាសី មានព្រះស្មារតីដឹងកាលណា
ប្រាកដជាក់ច្បាស់អនុជា ទ្រង់សោយសោការៀបរាប់ស្តី ៗ
ប្អូនអើយៗប្អូនប្រុសវរលក្ខណ៍ ចេញពីស្រុកយក្សមកឃ្លាតខ្ញុំ
វង្វេងវែកបាត់ប្អូនពីសី ប្រុសថ្លៃបងវេកអ្នកពុំឃើញ ៗ
រៀមជិះសេះស្ទាត់ត្រប់កន្ទេង ខំរកប្អូនឯងតែងអាសញ្ញ

តាមដានអស្ព្រាហ៍ម្ដេចពុំឃើញ ប្រុសប្អូនអញ្ជើញទៅខាងណា ៗ
ប្អូនអើយៗប្អូនមាសអណុាង អនុជនោមយំពន់សង្សារ
និរាសប្រាសព្រាត់បីឆ្នាំណា ទៅពេញស្នេហាបានជួបគ្នា ៗ
ប្រសិនបងដឹងបងមិនប្យាំង បងមិនតាំងឲ្យវេទនា
ចំណែកអនុជទៅកនិដ្ឋា បើជាបកិច្ចការមិនប្រាប់បង ៗ
កាលណោះព្រះបាទអនុជា ស្វាំងសោយសោកាទូលវិងស្នង
សូមទានបតិត្រព្រះបាទបង ពុំដឹងឡើយហោងអត់ទោសា ៗ
បើទូលបង្គំជាខ្ញុំដឹង រឿងនឹងមិនទាន់ឲ្យបែកការ
ខ្ញុំនឹងបញ្ឈប់ពលយោធា មិនឲ្យប្យាំងគ្នាបានឡើយនៃ ៗ
ហេតុនេះសូមទ្រង់មេត្តាប្រោស អភ័យឥតទោសព្រះបក្រី
សន្ដោសប្រោសប្រាណក្សត្រជាថ្មី នរបតីខ្ទីអនុជទៅ ៗ
ព្រះរៀមម្ចាស់ប្អូនកុំយល់ថា ខ្ញុំតបេស្ដានឹងព្រះចៅ
បើខ្ញុំតាំងទុកជាខ្មៅ ព្រះចៅមានគុណធ្ងន់វិសេស ៗ
ព្រះចៅឯកាពាក់ណាស់ ព្រះអនុជស្ដីគ្មានប្រហែស
ព្រះទ័យស្ដេចចង់វិលប្រទេស និវេសបុរីជសេមា ៗ
អនុជអង្វរព្រះរៀមរ៉ែ បពិត្របមប្រកអង្គក្សត្រា
អញ្ជើញស្ដេចយាងចូលសេមា សាកេតបុរីនៃយើងខ្ញុំ ៗ
ទូលព្រះបង្គំខ្ញុំអនុជ ឥតមានពុញថប់ព្រះបរម

យានភ្ជួនដំណើរក្សត្រិយ៍ឧត្តម ទៅដល់ក្រុងធំពារាណសី ៗ
ឲ្យទ្រង់ស្តេចយានចូលសេមា បុរីរដ្ឋនៃខ្ញុំខ្ញី
ឲ្យបានជ្រាបសព្វគ្រប់សេចក្តី ដល់ព្រះមហេសីនៃខ្ញុំផង ៗ
ឲ្យនាងបានស្គាល់ប្រាកដជាក់ ជាព្រះរៀមរ័កក្សត្របក្សបង្ស
កំសាន្តហឫទ័យលេងបានមួង សូមព្រះបាទបងយាងយាត្រា ៗ
កាលអឺយៗកាលនោះឯងនៃ ព្រះជេដ្ឋាថ្ងៃពុទ្ធឧក្ការ
អនុជក្រាបទូលអគ្គខត្តិយា ក្សត្រាទទួលដោយមេត្រី ៗ
កាលនោះព្រះបាទអនុជា ត្រាស់ហៅសេនានីសេនីយ៍
ដង្ហែបមបក្រនរបតី ពលពាលច្រើនក្រៃពីរនគរ ៗ
ឯពួកសេនីយ៍និងសេនា ឃើញអគ្គក្សត្រាមូលសាទរ
រមាត្យវង្សមានចិត្តត្រេកអរ ទាំងពីរនគរស្មោះចិត្តគ្នា ៗ
នាំគ្នាហែស្តេចពីរព្រះអគ្គ យាងចូលទៅក្នុងព្រះសេមា
លុះបានដល់វាំងទីប្រាង្គណ៍ប្រា សាទរត្រៃថ្ងៃថ្វាអនុជនាថ ៗ
កាលអឺយៗកាលនោះបវរ មូលីសុន្ទរចូលអភិវាទន៍
ព្រះរាជស្វាមីនៃនាងនាដ តាមជាតិជាក្សត្រខត្តិវង្សា ៗ
ព្រះអនុជាបង្គាប់ខ្ញី នៃមូលីស្រីស្រស់ពុំអា
បង្គំព្រះរៀមជាជេដ្ឋា ណាស្រស់កនិដ្ឋាព្រលឹងបង ៗ
ព្រះនាងលើកហត្ថពីរខ្ញីឃ្មាត អភិវាទតាមព្រះបន្ទូលស្នង

ដែលព្រះស្វាមីបង្គាប់ផង　　នាងគ្មានរំលងដល់តិចឡើយ ។
ទើបនាងមានព្រះសវនីយ៍　　ទូលព្រះរៀមថ្លៃក្សត្រត្រាណត្រើយ
ខ្ញុំត្រេកអរណាស់ម្ចាស់ម្លូនអើយ　　បានឃើញកក្រុះហើយក្នុងថ្ងៃនេះ ។
ព្រះស្វាមីនៃខ្ញុំម្ចាស់　　ស្ដេចមានតម្រាស់ថាដូច្នេះ
ដំណាលប្រាប់កាលស្ដេចគង់សេះ　　ចេញចាកទិវេសបែកបាត់ឋាន ។
ស្កាត់រកបមកពគ្រប់កន្លែង　　ដល់នគរហ្វូរល្អងសព្វក្នុងស្ថាន
ណាក្មេងរលប់បាត់អស់ឋាន　　រករៀមកល្យាណពុំឃើញសោះ ។
កាលក្រោយប្រាស់ព្រាត់ពីព្រះអង្គ　　បានមកនៅក្នុងនគរស្មោះ
នឹងផ្ទះយាយតាមានសប្បុរស　　គាត់នោះផាដាយបង្ខុឲ្យាន ។
ស្រាប់តែព្រះវរពដបិតា　　ទ្រង់មានអាពាធមកបៀតបៀន
ស្ដេចទិវង្គតពីកដស្ថាន　　ក្សត្រិក្សត្រិយានទៅកាន់បរលោក ។
ក្រោយនោះសម្ដេចព្រះជននី　　រៀបធ្វើពិធីថ្វាយក្មេងលោក
លុះយូរបន្តិចស្ដេចអន់សោក　　ទើបទ្រង់ផ្សងរកអ្នកមានបុណ្យ ។
មាតាលោកផ្សងនឹងដំរី　　បុស្សរតន៍ថ្វាថ្លៃប្រសើរលន់
អង្គព្រះអនុជថ្លៃលើជន　　ដំរីនាំមុនចូលបុរី ។
សម្ដេចមាតានឹងអមាត្យ　　ព្រាហ្មណ៍បារគ្គបុរោហិតខ្ទី
សម្ដេចព្រះអនុជគ្រង់បុរី　　អភិសេកចំៗនឹងខ្ញុំផង ។
មូលីសុន្ទរស្រីវរលក្ខណ៍　　នាងទូលតាមថ្នាក់ដល់រៀមបង

ព្រះបាទឯកាជ្រាបហើយហោង ច្បាស់ច្បងស្រងូតស្ងួតក្រា ។
ព្រះបាទឯកាពារាណសី មានបន្ទូលឲ្យថាកនិដ្ឋា
តាំងពីរមាសបងៗយាត្រា នាំតាំងទ្វេហាទៅនគរ ។
ទៅលេងទីនបងកំសាន្តចិត្ត យើងអស់ភ័យគិតហើយបវរ
ឲ្យបានសុវណ្ណស្រីអម្ត នាងទីនឧបអរជាមួយផង ។
កាលនោះព្រះបាទអនុជា ប្រាប់វរជាយាមហេសីស្នង
តាក់តែងប្រដាប់ឲ្យឆាប់ផង ទីនជូនរៀមបងទៅនគរ ។
ទើបទ្រង់បង្គាប់ពលសេនីយ៍ ឲ្យរៀបដំរីសេះកុះករ
អមាត្យរៀបស្រេចទុកបញ្ជរ ចាំក្សត្របវរតែងព្រះកាយ ។
រូបស្រេចស្ដេចគង់លើដំរី ក្សត្រាក្សត្រិយ៍បីដោមឆាយ
ផ្ដាំអស់នាហ្មឺនទាំងពលនាយ នៃអ្នកទាំងឡាយថែនគរ ។
ទើបស្ដេចយាងចេញចាកសាកេត បុរីចើងថានថ្ងៃបវរ
សំដៅពារាណសីនគរ ពលពាលកុះករហែត្រៀបត្រាៗ
ស្ដេចយាងចូលក្នុងរាជវាំងជ័យ ចុះពីដំរីបីអគ្គា
ទើបយាងគង់ឡើងលើប្រាង្គណ៍ប្រា សាទរត្ថៃថ្លាប្រសើរក្រៃ ។
កាលនោះសុវណ្ណអម្តស្រស់ រូបល្អលើសអស់ស្នំដទៃ
ចូលថ្វាយបង្គំព្រះស្វាមី នាងត្រេកអរក្រៃឥតឧបមា ។
ទើបនាងមានព្រះសវនីយ៍ បពិតក្សត្រថ្លៃខ្ពស់ដេជ្ជា

ខ្ញុំម្ចាស់បង់ដឹងដំណើរណា　ទាំងពីរទេ្វហាត្រូវដូចម្តេច ៗ
កាលនោះឯកាជាស្វាមី　ឮព្រះមហេសីស្រស់ដូចពេជ្រ
ព្រះឱស្ឋប៉ប្រិមញញឹមគេជ　ត្រាស់សួរពីស្តេចទាំងទេ្វហា ៗ
ទើបស្តេចមានព្រះបន្ទូលខ្វី　ថានែប្អូនស្រីដួងចិន្តា
ទាំងពីរក្សត្រិយ៍នឹងក្សត្រា　ត្រូវជាកនិដ្ឋាបង្កើតបង ៗ
កាលអីយកាលនោះអនុជា　មូលីសុន្ទរស្រស់នួនល្អង
លើកហត្ថបង្គំក្សត្រិយ៍បង　ដោយពាក្យសារសងសព្វបា ៗ
ក្សត្រិយ៍ក្សត្រាប្អូនព្រះអគ្គ　ស្តេចគង់ហង់ដូចទេវតា
សុវណ្ណអម្ពជិតឯកា　សុន្ទរជីតាជិតអនុជា ៗ
ដោយទ្រង់លើកនឹកមហេសី　ឃ្លាតគ្នាយូរថ្ងៃកក្ខចិន្តា
ទើបទ្រង់ឲ្យរៀបគ្រែសយនា　ថ្វាយអនុជានឹងសុន្ទរ ៗ
ប្រាសាទដទៃដាច់ពីគ្នា　ទ្រង់នាំជាយាស្រសបវរ
ព្រះអនុជានឹងសុន្ទរ　សុវណ្ណអម្ពនឹងឯកា ៗ
ទ្រង់យាងចូលផ្ទំដោយសុខសាន្ត　សម្រាកសម្រាន្តព្រះកាយា
ទាំងពីរនាងនឹកព្រះភស្តា　តម្រេកតណ្ហាឥតឧបម័យ ៗ
លុះព្រឹកក្តីស្វាងបំព្រាងព្រះ　សុរិយារៀងរះឧណោទ័យ
ទាំងប្អូនក្សត្រាតើនបាកស័យ　បេញកងភេរជ័យមន្ត្រីគាល់ ៗ
ទើបស្តេចដំនុំនឹងមន្ត្រី　ដោយព្រះហឫទ័យទ្រង់ពីធល

នឹងព្រះអនុជានិមល　　មហេសីសោកសល់តាំងពីផង ។
ព្រះបាទឯកាថាប្អូនអើយ　　ចំណេកមាតាបិតាបង
ប្រាប់ឃាតករណាសមកហើយហោង　　ម្ល៉េះសំនឹកបងនឹងអនុជ ។
មហេសីតាំងពីលើកហត្ថា　　ក្រាបទូលក្សត្រាឥតមានទប់
ដល់ព្រះរៀមថ្លៃនឹងអនុជ　　ឥតមានបន្ទូចព្រះហឫទ័យ ។
ទើបនាងទូលថាបើដូច្នោះ　　សូមព្រះទ្រង់យសជ្រាបសេចក្ដី
យានតាំងព្រះអង្គខ្ញុំមហេសី　　នឹងអនុជថ្លៃតាំងពីប្រាណ ។
ពួកពលតាំងពីព្រះនគរ　　ច្រើនក្រៃកុះករពន់ប្រមាណ
ដង្ហែចេញពីព្រះរាជស្ថាន　　នឹងបានទៅដល់ព្រះមាតា ។
ព្រះបិតានៅឯស្រុកនាយ　　លោកបានរីករាយព្រះបិន្ទា
ព្រោះវង្សបានឃើញរាជបុត្រា　　ដែលព្រាត់ឃ្លាតឃ្លាមកប្រូវហើយ ។
កាលនោះព្រះបាទអង្គឯកា　　ពុរជាយាទូលថ្លាប់ឆ្លើយ
ថាពាក្យប្អូនស្រីស្ដីត្រូវហើយ　　ប្អូនអើយកំណត់បីខែទៀត ។
ទឹងទៅអញ្ជើញព្រះជននី　　ជនកតាំងពីកុំឲ្យឃ្លាត
នៃអស់មន្ត្រីនឹងអមាត្យ　　តែបីខែទៀតយើងនឹងទៅ ។
តែថាឥឡូវបងសូមប្រាប់　　សេចក្ដីសារស័ព្ទឲ្យប្អូនពៅ
តាំបីអង្គប្រាណបានជ្រាបនូវ　　សេចក្ដីខុសត្រូវជួយពិគ្រោះ ។
កាលបងទៅនៅនឹងស្រុកយក្ស　　បានផ្ដាំជាក់លក្ខណ៍នឹងបងស្មោះ

គ្រប់ប្រាំមួយឆ្នាំវិលវិញចុះ យក្សនោះប្រាប់ថាកុំឲ្យខាន ។
សូមបើងជាកូនទាំងពីរនាក់ ឲ្យទ្រព្យទាំងប្អូនប្រការបាន
យើងជាកូនធម៌យក្សកល្យាណ ដូចនេះត្រូវខានឬត្រូវទៅ ។
ហេតុនេះត្រូវប្អូនជួយពារគ្រោះ ពាក្យនោះប្រគល់ឲ្យស្រីពៅ
ទាំងពីរនាងឆ្លើយមកនោមខ្លៅ ឲ្យទៅឬនៅនាងប្រាប់បង ។

សុវណ្ណអម្ពទឹងម្លី- សុន្ទរនារីនាងឆ្លើយស្នង
ស្ដេចយក្សមានគុណក្រៃកន្លង សូមព្រះបាទបងយាងកុំខាន ។
ក្រៃងយក្សមានការកិច្ចអ្វីៗ នឹងព្រះបក្រក្សត្រកល្យាណ
បានជាទ្រង់ផ្ដាំកុំឲ្យខាន ប្រាំមួយឆ្នាំបានឲ្យវិលវិញ ។
នាងខ្ញុំទាំងពីរពុំដឹងកិច្ច ជាការម្ដេចៗកុំតោម្ញេញ
តែបាព្រះអង្គចាប់វិលវិញ នឹងយាងទៅតាមព្រះមាតា ។
បិតាទៅស្រុកឯនាយនៃ ឆ្ងាយពន់ពេកក្រៃក្នុងព្រឹក្សា
ម៉្ងេះសំមើលផ្លូវដល់បុត្រា ចាប់វិលវិញណាព្រះបាទបង ។
កាលនោះព្រះបាទអនុជា ហៅអស់សេនាមន្ត្រីផង
ឲ្យហៅក្សត្រីយ៍ស្រីទូលល្អង វិលបុរីផ្គងរាជសេនា ។
កាលអង្គក្សត្រាទាំងពីរប្រាណ លាមហេសីបានស្រេចកាលណា
ចេញចាកពីក្រុងព្រះភាក សំដៅសេមានគរយក្ស ។
រឿងនេះឈប់ស្ទះមិនចរចា សូមថ្លែងពណ៌នាទៅតាមថ្នាក់

ស្រដីតំណាលពីស្រុកយក្ស　　កើតមានចំពាក់ពាក់ចងគ្នា ៗ
កាលពីយកាលនោះក្រុងអសុរី　　មានល្បីឮតាពោរសេមា
ក្រុងយក្សដទៃខ្លាចគ្រប់គ្នា　　អសុរីក្រុងមារឈ្មោះមហាមេឃ ៗ
ស្តេចមានឯកអគ្គមហាមហេសី　　សុវណ្ណកេសីល្អបំផ្លែក
ទើបក្រុងអសុរាលើកជាឯក　　ល្អថ្លៃកលើសអស់ស្ត្រីទាំងឡាយ ៗ
មានបុត្រាមួយឈ្មោះមហាតាល　　ជាបុត្រគ្រាកាលបេះសិល្បសាយ
បេះទាំងសណ្តំបេះទាំងស្រាយ　　បេះទាំងថ្វីងកាយបេះនិម្មិត ៗ
បេះល្បីសិល្បសាស្ត្រលើសអស់យក្ស　　គ្មានទើសគ្មានពាក់អំពីរិទ្ធិ
រៀនពីឥស្សរគ្រូកែពិត　　ក្លីក្លើឲ្យល្បិតបានទាំងអស់ ៗ
ថ្លៃងពីមហាមេឃជាបិតា　　ត្រងរាជសេមានៅក្នុងកោះ
កណ្តាលសមុទ្រក្តំទាំងអស់　　ឈ្មោះកោះគិរីរាជបុរី ៗ
យក្សមានពលរេហ៍សេនាច្រើន　　រាប់រយពាន់ហ្មឺនបុទ្ធក្រៃ
នៅក្នុងទីក្រុងអសុរី　　មានល្បីឫទ្ធិសព្វស្ថាន ៗ
រឿងនេះខ្ញុំសូមដោយនិទាន　　តំណើរដើមចងតាមដោយដាន
ក្រុងពេជ្របុរីព្រះរាជស្ថាន　　ក្សេមក្សាន្តឥតមានទុក្ខភ័យា ៗ
យក្សវិរុឡ្ហ មាត្យនឹងមហេសី　　នាមវរក្សត្រីយ៍ស្រីចន្ទ្រា
បុត្រីស្រីចន្ទ្រ៍បទុមា　　ល្បីល្អអស្ចារ្យក្នុងបុរី ៗ
ព្រះជន្មបានដប់ប្រាំមួយឆ្នាំ　　ស្រស់ឆាំស្រស់ឆើតត្រួតប្រឹមប្រិយ៍

ទ្រលុកទ្រលន់សាច់ទន់ខ្ចី កេសីរលន់ទ្រន់រលើប ។
សាច់សល្អស្អាតហ្មត់ផូរផង់ ត្រប៉ះត្រចង់គួរឲ្យស្រើប
មើលថ្ពាល់ទាំងពីរគួរប៉ង់ថើប បំពើបបំពាក់ចិត្តគ្រប់គ្នា ។
នេះពេញហៅល្អក្នុងបុរី ពួកព្រឿទូរទៅគ្រប់ទិសា
តម្ណឹងដល់ក្រុងអសុរា នគរនាមថាកោះគិរី ។
កាលនោះមហាមេឃក្រុងអសុរី ផ្តាំអគ្គមហេសីជាទេពី
ថានៃឆោមស្រស់អស់នារី បងចេញទៅទីពេជ្របុរី ។
តម្ណឹងថាបន្ទុំបទុមា បុត្រីអសុរាល្អលើសស្រី
បើឃើញត្រូវចិត្តបង់គិតស្តី ត្រឡប់វិលវៃរៀបកស្តការ ។
ដូចនេះនាងនៅចាំរាំងជ័យ មើលអស់សេនីយ៍ស្រីស្រឹង្គារ
លាស្រេចស្តេចចាប់ដម្បងថ្វា ពេជ្រហោះវេហាស៍សំដៅទៅ ។
រំលងសមុទ្រគិរីត្រៃ លើអាកាសស័យខ្ពស់សន្ធៅ
យក្សហោះលឿនលន់ពន់ពេកក្រៃ លុះបានដល់ទៅពេជ្របុរី ។
ទើបក្រុងអសុរីចរចុះផ្គង ដល់ស្រេចហើយហោងលើផែនដី
ហត្ថកាន់ដម្បងចូលឃ្លាតខ្ចី មហាមេឃអសុរីដល់ខ្លោងទ្វារ ។
ដល់ហើយសូមចូលក្នុងរាជវាំង យក្សយាមថាចាំទូលរាជា
ព្រះនាមអ្វីទៅនៅស្រុកណា ឲ្យក្រុងអសុរាស្តេចទ្រង់ជ្រាប ។
ឯយើងនេះឈ្មោះក្រុងមហាមេឃ បុរីឯកកោះគិរីរាប

ទៅទូលក្សត្រាឲ្យបានជ្រាប　តាមដោយសភាពសព្វសេចក្ដី ៗ
អមាត្យយាមទ្វារចូលសំដៅ　អង្គព្រះបមពៅពេជ្របុរី
ទូលថាបពិត្រព្រះនរបតី　មានក្រុងអសុរីចូលសូមជួប ៗ
អមាត្យក្រាបទូលតាមដំណើរ　ទើបក្សត្រប្រសើរទ្រង់រួមរួប
ឲ្យចូលមកចុះបើចង់ជួប　សម្រួមសម្រួបពីការអ្វី ៗ
អមាត្យយក្សថ្វាយបង្គំលា　មកដល់ខ្លោងទ្វាររំពេចខ្ញុំ
ប្រាប់ដល់មហាមេឃអសុរី　ចរចូលឆាប់វៃដល់ក្សត្រា ៗ
កាលនោះវិរុឡ្ហមាត្យក្រុងអសុរី　ស្ទុះមកចាប់ដៃមហាមេឃណា
ថាយីក្មួយឯងមកមានការ　ប្រាថ្នាអ្វីណាប្រាប់យើងផង ៗ
មហាមេឃឆ្លើយប្រាប់ថាក្មីអើយ　យើងមកនេះហើយមានបំណង
ប្រាថ្នាចង់ធ្វើជាតន្វង　ល្បីបុត្រីស្ងួនដល់ទៅខ្ញុំ ៗ
ថាល្អឥតមានទាស់ត្រង់ណា　ចង់ឃើញធីតាបន្ទូរ៍បទុម
ដូចនេះក្មីអើយយើងសូមសុំ　មើលកូនក្រមុំក្មួយបានម្ដង ៗ
ក្រុងវិរុឡ្ហមាត្យអង្គអសុរី　ពុំមហាមេឃស្ដីថាបំណង
នឹងគិតចង់ធ្វើជាតន្វង　វិរុឡ្ហមាត្យឆ្លើយធ្វង់ថាក្មីអើយ ៗ
ចង់មើលបានដែរតែកូននេះ　បំពាក់ពាក់ចិននឹងគេហើយ
ការនេះមិនកើតទេក្មីអើយ　បើខ្ញុំព្រមឲ្យមានរឿងធំ ៗ
ពីព្រោះកូននេះឲ្យទៅគេ　តាំងពីអាយុនៅដប់ឆ្នាំ

សព្វថ្ងៃខ្ញុំនៅតែរង់ចាំ គ្រប់ប្រាំមួយឆ្នាំៗនឹងហើយ ៗ
វិរុឡ្ហាមាត្យប្រាប់សព្វគ្រប់ មហាមេឃអសុរីថាក្រើអើយ
បើប្តោះនាំនាងចេញមកហើយ បំណាច់យើងកាត់មកពីឆ្ងាយ ៗ
ចង់ឃើញឲ្យជាក់ច្បាស់នឹងភ្នែក ល្បីល្អចម្លែកលើសស្រុកឆាយ
ជាមែនឬទេគេអធិប្បាយ តាមពាក្យខ្ចរខ្ចាយថាល្អណាស់ ៗ
ក្រុងវិរុឡ្ហាមាត្យអង្គអសុរ ហៅព្រះមហេសីស្រីឆោមឆាយ
នៃវិរចន្ទ្រាស្រស់កបកាយ ឆើតឆាយហៅចន្ទ័បទុមា ៗ
បុត្រីនៃយើងឲ្យមកឆាយ ឪពុកឲ្យហៅមកមានការ
ឲ្យនាងចូលមកឆាប់ៗពី កុំស្រស់ធីតាបង្អង់ឡើយ ៗ
កាលនោះក្សត្រិយ៍ស្រីចន្ទ្រា ពុស្សាមីណាប្រែនាងហើយ
ទើបមានសវនីយ៍ស្តីឆ្លងឆ្លើយ ប្រាប់កិលៀនឲ្យហៅប្រញាប់ ៗ
កិលៀនដើរដល់ប្រាង្គណ៍ប្រាសាទ ស្រីស្រស់ឆោមស្អាតទូលប្រញាប់
បពិតក្សត្រិយ៍សូមសណ្តាប់ បីតាបង្គាប់ឲ្យព្រះនាង ៗ
យាងទៅជំណាក់ព្រះបិតា ឲ្យឆាប់រួសរ៉ាតាមសូរសៀង
ទ្រង់ស្តេចមានការដល់ព្រះនាង ឲ្យយាងប្រញាប់ឆាប់កុំខាន ៗ
ទើបនាងទ្រង់តែងព្រះកាយា ប្រហែលកញ្ញាកញ្ញុំសួគិស្ថាន
ចុះចាកពីប្រាង្គណ៍ស្រីកល្យាណ កិលៀនពីរប្រាណដង្ហែមក ៗ
ចន្ទ័បទុមាស្រស់ពន្លឺក ពន្លឺដូចទឹកដែលរលក

សម្បុណ៌រលង់ដូចគេយក មកខាត់រលីងទៀងរលោង ។
សុគន់តាំងគូរដូចបទុម រៀបរីកក្រពុំទ្រង់សម្ពោង
ត្រសុំត្រសូលកន្ត្រាឈ្នង បំព្រងញញឹមខឹមជិតស្ហា ។
ស្រលួតស្រឡះសាច់ហ្មតសូន្យ មើលមិនឆ្អែតចិត្តជាប់ចិន្តា
ល្អនេះហៅល្អសរូបា ល្អគ្មានស្រីណាមកផ្ទឹមបាន ។
នាងយាងមកដល់ព្រះបិតា មាតាក្សត្រិយ៍ស្រីកល្យាណ
លើកហត្ថតាំងទូអញ្ជលីដ្ឋាន បង្គំក្សត្រក្សាន្តតាំងទេហា ។
នាងមានសទើយ៍ថាបពិត បិតាទ្រង់រង្វើ៍មានកិច្ចការ
ថាឲ្យខ្ញុំមកឆាប់រួសរ៉ា តើព្រះបិតាមានការអ្វី ។
វិរុឡ្ហាមាត្យអសុរជាបិតា បុត្រីទូលថាសព្វសេចក្តី
ទើបស្តេចឆ្លើយថានៃកូនស្រី មហាមេឃអសុរចង់ឃើញកូន ។
កាលនោះមហាមេឃអសុរយក្ស ឃើញហើយស្ញើភ្ញាក់ថ្ងើមបាត់សូន្យ
ដូចគេកន្ត្រាក់ញ័ររស់ខ្លួន ស្មារតីឈឹងសូន្យពុំដឹងប្រាណ ។
ភាំងមើលក្សត្រិយ៍ស្រីវិលក្ខណ៍ ដោយមានចិត្តស្ន័ត្រឹងកល្យាណ
សំទឹងកូនប្រុសស្រស់កុំផាន បើបានជាគូរមេឃាស្នា ។
ម៉្លេះសំពេញចិត្តស្នេហ៍មេត្រី សុវណ្ណគេសីមហេសីណា
ម៉្លេះសំពេញចិត្តភពបុត្រា មហាកាលអសុរាជាកូនប្រុស ។
មហាមេឃអសុរស្តីទៅថា នឹងវិរុឡ្ហាមាត្យបើដូច្នោះ

ក្ដីអើយកូននេះទុកឲ្យបុះ ទោះបីត្រូវខុសស្រេចលើខ្ញុំ ៗ
វិរុទ្ធមាត្យថាមិនបានទេ គ្មានកូនទំនេក្ដីកុំ ៗ
បើខ្ញុំបរះបសកើតរឿងធំ ក្ដីអើយអ្នកកុំគិតដូច្នេះ ៗ
កូនស្រីឲ្យមានប្ដីរួចហើយ ក្ដីរើយខ្ញុំមិនបេះគេបវេះ
ធ្វើពាក្យសច្ចៈកុំឲ្យទេះ ទោះស្ដេចទោះរាស្ត្រពោលទៀងត្រង់ៗ
មហាមេឃពោលថានែក្ដីរើយ ពាក្យថាបេះហើយមិនឈ្នះបង់
ធម្មតាប្រាជ្ញាមិនឈ្នះល្ងង់ ធម្មជាតិអ្នកត្រង់មិនឈ្នះពាល ៗ
ធម្មជាតិខាងកើតមិនឈ្នះស្លាប់ ច្បាប់ជាឯកិច្ចមិនឈ្នះកល
យើងធ្វើក្បៀមៗគោងយកផល ខ្វះអ្វីកិច្ចកលយើងធ្វើកើត ៗ
ខយើងសន្យាប្រាំមួយឆ្នាំ ឥឡូវយើងចាំឥតក្ដើនក្ដើត
ហួសប្រាំមួយឆ្នាំយើងកែកើត ក្ដីរើយបំផើតបំផុតកល ៗ
មហាមេឃអសុភគិតខែឆ្នាំ រាប់តាមចំណាំដប់ខែសល់
លើសប្រាំមួយឆ្នាំដោយកិច្ចកល ក្ដីរើយចាំដល់ណាទៅទៀត ៗ
បើបេ្ចះខ្ញុំវិលទៅបុរី គិតចូលមកស្ដីដោយធុះឆៀត
ខ្ញុំស្ដីរួចហើយគិតការទៀត ត្រង់ការវាទស្រេចលើខ្ញុំ ៗ
មហាមេឃអសុភលាវិលវិញ ហៀរហោះចេញកឹងបុរីរម្យ
វិលងសមុទ្រភលព្រៃភ្នំ ដល់បុរីធំកោះគិរី ៗ
យក្សប្របុះផ្គងចូលភាំងវៃ ត្រាស់ហៅមហេសីផាទេពី

នឹងបុត្រាមកជុំតាំងទ្វី នៃអ្នកទាំងពីរចូលចាំស្ដាប់ ៗ
ដំណាលពីចន្ទ៍បទុមា ស្រីក្នុងលោកាគ្មានតម្រាប់
នឹងយកមកប្រៀបប្រដូចប្រាប់ ស្រីស្រស់ចំណាប់ឥតផ្ទឹមបាន ៗ
ពេញហៅថាល្អសព្វអស់អង្គ ត្រចះត្រចង់ស្រីកល្យាណ
ពន្លឺភ្លឺដូចកែវសុរិកាន បើបានរួមប្រាណនឹងកូនយើង ៗ
សមជាមហេសីស្ដេចសោយរាជ្យ សមមានអំណាចបុណ្យថ្កុំថ្កើង
សមនឹងសក្ដិយសនគរយើង នឹងបានរុងរឿងថ្កើងតទៅ ៗ
ទើបចាត់ឲ្យរៀបបណ្ណការ អ្នកផ្ញើទៅមហាចូលថៃបូរ
តណ្ដឹងតាមច្បាប់ពីម៉ែឪ ធ្វើតាមតម្រូវតម្រាយចាស់ ៗ
មានគ្រប់ប្រដាប់កស្ដការផង ច្រើនក្រៃកន្ទុងពន់ពេកណាស់
ជ្រូកក្ដាន់មាន់ទាខ្វៃពុះវះ ច្រើនណាស់រាប់រយគ្រប់ៗមុខ ៗ
ចំណែកផ្លែឈើមានសព្វគ្រប់ បេកដូងខ្នាស្វាយរៀបដាក់ទុក
ចំណែកកវាន់ទំរៀបដាក់ស្នុក មានគ្រប់ ៗ មុខគ្មានខ្វះអ្វី ៗ
ទើបស្ដេចឲ្យរៀបពលយោធា ទាហានសេនាមុខមន្ត្រី
កាំភ្លើងតូចធំដាវវែងខ្លី ចេញចាកបុរីកោះគីរី ៗ
ហោះឆ្លងសមុទ្រវាលព្រៃធំ ដង្ហោលដង្គុំទៅមេឃមីរ
សុទ្ធតែពួកយក្សញ័កប្រថពី ញ័រទាំងគិរីព្រៃព្រឹក្សា ៗ
លុះដល់ក្រុងពេជ្របុរីរម្យ យក្សចរចុះជុំពេញត្រៀបត្រា ៗ

ស្តេចឲ្យសង់ពេនព្រះពន្ធា ទទួលយោធាជាន់ជប់ហ៊ឹន ។
ទើបក្រុងមហាមេឃទ្រង់ត្រាស់ថា ឲ្យរៀបកស្ករថា យ៉ាងច្រើន
របស់ណាតិចជាកបង្កើន រៀបឲ្យច្រើនៗសមនឹងគុណ ។
នំដាក់ដោយនំម្ហូបដោយម្ហូប ចំណែកផ្លែឈើដាក់គ្រប់មុខ
មុខណាដាក់ដល់គ្រប់វេយតុ សឹងមានគ្រប់មុខមិនឲ្យខ្វះ ។
មហាមេឃអស់ឲ្យលើកឡើង លើប្រាសាទថ្កើងថ្កានត្រចះ
កាន់គ្រឿងកស្ករនាប់រូតរះ តាមព្រះបន្ទូលក្រុងយក្ស ។
មហាមេឃអស្កុកនាំមហេសី នឹងបុត្រាខ្ទីអ្នកផ្ទៃមហា
នឹងពួកសេនីយ៍ស្រីស្រគ្គា ឡើងគាល់អស្កុកវិរុឡ្ហកមាត្យ ។
ដល់ហើយអង្គុយនៅត្រៀបត្រា លើទីប្រាង្គណ៍ប្រាប្រះសីស្អាត
មហាមេឃឲ្យកូនក្រាបអភិវាទ ដល់ក្រុងវិរុឡ្ហកមាត្យជាបិតា ។
ហើយឲ្យសំពះមាតាក្មេក ស្រីស្រស់ចម្ពូកវរបន្ទា
ហើយឲ្យសំពះយក្សរាមា ដែលជាមេបាកន៍ទីនោះ ។
ហើយទើបមេបាយក្សប៉ុន្មាន អង្គុយរៀបប្រាណតាំងស្រីប្រុស
លើប្រាង្គណ៍ប្រាសាទច្រើនប្រូងប្រុះ តាំងពួកវានប្រុសក៏ច្រើនណាស់ៗ
ហើយទើបអ្នកផ្ទៃនឹងទៅមហា ថ្វីនំពោលពាក្យាដោយរអាស់
ថាខ្ញុំមកពីស្រុកឆ្ងាយណាស់ ប្រាថ្នាស្ងួនសូរះចូលមកដល់ ។
សូមទានមេបាតាំងប៉ុន្មាន អង្គុយរៀនប្រាណកុំនឿងឆ្ងល់

យើងខ្ញុំប៉ុន្មានបានមកគាល់
សូមទានបង្គាល់កូនស្រីលោកៗ
ដើម្បីតណ្ហាំងថ្វាយបុត្រា
ក្រុងអសុកស្ដេចមានជោគ
ផ្សំផ្គុំនឹងកូនរបស់លោក
ឲ្យសោយរាជ្យក្រុងរដ្ឋបុរី ៗ
កាលនោះវិរុឡ្ហមាត្យវរចន្ទ្រា
ឲ្យហៅធិតាស្រស់ប្រិមប្រិយ៍
តែងគ្រឿងប្រដាប់ឆាប់ៗខ្ចី
អម្ពរស្រស់ខ្ចីស្រីឆោមឆាយ ៗ
ប្រហែលដូចជាកូនទេវតា
បុះពីសួគ៌ាមកនៅអាយ
ទ្រង់គ្រឿងប្រដាប់សម្រាប់កាយ
អលង្ការទាំងឡាយល្អឥតផ្ទឹម ៗ
ថ្ងៃពីចិត្តនាងបទ្ង៍បទុម
ទ្រង់ទឹកបារម្ភគ្មានសង្ឃឹម
លង្ងង់លង្ងោចង្ងាយលង្ងឹម
ទទឹមទទឹងព្រះស្វាមី ៗ
ឌុះឌុព្រះបងអស់បានយល់
ប្អូនកើតទុក្ខទល់រាល់រាត្រី
ម្ដេចបាត់សូន្យឈឹងដូច្នេះនៃ
ឲ្យប្អូនមមៃរាល់វេលា ៗ
នាងតែងខ្លួនស្រេចចរចុះផ្គង
កីលៀងពីរផងហៃធីតា
សំដៅប្រាសាទព្រះបិតា
ដល់ស្រេចហើយណាវន្ទាខ្ចី ៗ
ពួកយក្សអង្គុយនៅត្រៀបត្រា
ឃើញនាងធីតាវរក្សត្រិយ៍
ត្រចង់ត្រចះដូចទេពស្រី
យក្សលាន់មាត់ស្ដីថាយីអើ ៗ
នេះពេញហៅល្អក្នុងបុរី
ឥតមានស្រីណាប្រដូចស្មើ
ល្អអីហៅល្អស្រស់ប្រសើរ
គួរឲ្យចង់មើលមិនដាក់ភ្នែក ៗ
ថ្ងៃពីឯកអង្គអសុកបុត្រ
ឃើញនាងប្រាកដបទយល់ថ្លែក

ឃើញហើយមើលសឹងមិនដាក់ភ្នែក  ល្អនេះល្អឯកចម្លែកស្រី ។
គិតថាម៉្លេះហើយយកឲ្យបាន  ទុកក្នុងទីស្ថានរួមបេតី
ដម្កុំដម្កើងឡើងលើសស្រី  គួរឲ្យមេត្រីក្តីស្នេហា ។
កាលនោះនាងចន្ទ៍បទុមស្រី  ឃើញបុត្រអសុរីនាងខ្លាចផ្សា
នឹកដល់ពលឯកអគ្គបក្កព  ដែលជាស្វាមីប្តីនាងមុន ។
នាងថ្វាយបង្គំព្រះបិតា  ក្រោកចាកអាស្នា កាយទោរទន់
នឹកព្រះស្វាមីស្រីពេកពន់  ទឹកភ្នែកជោរជន់ហូរដល់ដី ។
កើលៀងតាំងពីរដៃន្ហៅ  នាំនាងស្រីពៅចរចេញខ្វី
ឡើងលើប្រាសាទវរក្សត្រិយ៍  នាងឥតស្តីរកស្ត្រណាឡើយ ។
នាងយាងឡើងលើគ្រែសុវណ្ណា  បិទបាំងសន្ធិយាជិតជុំហើយ
ព្រះនាងទ្រង់គេងទៅលើខ្នើយ  ទឹកភ្នែកឥតស្បើយជោគកក្រ្តា ។
ទង្គិះក្បែកក្បាលអួលបុកណែន  ទុក្ខនេះហៅសែនតឹងនុក៉
តឹងអឺយតឹងម៉្លេះមិនបេះថា  ឥតមាននរណាជួយខ្ញុំផង ។
ឱះឱស្វាមីប្តីស្នេហា  លែងឃើញក្រ្តាប្អូនហើយហោង
ពេលនេះប្អូនខ្សោយចោលព្រះបង  ម្តេចប្រុសស្នេហ៍ស្ងួនមិនមកនាប់ ។
សោកហើយសែនសោកបោកអគ្គប្រាណ ខ្លួនអើយម្តេចបានស្លាប់ប្រញាប់
កោតចិត្តព្រះបងមិនមកឆាប់  ឲ្យទាន់ប្អូនស្លាប់បានឃើញមុខ ។
ឥឡូវគេមកគិតរៀបការ  នឹងប្អូនហើយណាយកទៅស្រុក

ក្តៅអីយសែនក្តៅសៅរែតក្ក　　អស់បានឃើញមុខបងទៀតហើយ ៗ
គូអីយគូព្រេងវេវ្ទនព្រាត់　　ប្រាស់ចោលប្អូនបាត់ម៉ែនមកឡើយ
សង្សារគូគមមកដល់ហើយ　　ព្រេងអីយធ្វើម្តេចបានជួបគ្នា ៗ
នាងលើកដៃឡើងផ្សងព្រះឥន្ទ្រ　　កោសិន្ទ្រនៅកងស្ថានសួគ៌ា
សូមឲ្យលោកជួយខ្ញុំផងណា　　ខ្ញុំមានទុក្ខានឹកស្វាមី ៗ
នាងសោកអស់មួយរាត្រីយប់　　តាំងពីព្រលប់ដល់ស្មើ
សុរិយាឡើងរះខណ្ណាច័យ　　ក្សត្រិយ៍នាងផ្តុំក្រោកឡើយ ៗ
លុះដល់ពេលព្រឹកម៉ោងប្រាំបី　　អ្នកផ្ទះចៅមហាឡើងមកហើយ
ឲ្យនាំកូនស្រីមកជុំខ្ទើយ　　ស្រេចហើយបងដៃទឹងសំពះ ៗ
អ្នកផ្ទះផឹកបចៅមេបា　　ព្រមទាំងអ្នកមហាសូមប្រសាទ
ឲ្យនាំកូនស្រីធាប់ហោស់　　ដល់ពេលសំពះដិតណាស់ហើយ ៗ
ឯក្រងអសុរាពេជ្របុរី　　ប្រើគីលៀងខ្ញុំថានាងអើយ
ទៅហៅបុត្រីស្រីស្រស់ហើយ　　ត្បិតបិតាឲ្យមកប្រញាប់ ៗ
គីលៀងផ្ទៀងស្តាប់ត្រីទុក្ខា　　ទៅដល់ធីតាជួបបង្គាប់
បពិត្រព្រះនាងយាងឲ្យឆាប់　　ប្រញាប់ឲ្យទាន់ព្រះបន្ទូល ៗ
ព្រះនាងទ្រង់គ្រឿងមលក្កា　　រូបស្រេចកាលណានាងយាងចូល
រួសរាន់ឲ្យទាន់ព្រះបន្ទូល　　បវចូលទៅជិតព្រះបិតា ៗ
ព្រះនាងទៀងទូលថាបពិត្រ　　សូមទានទ្រង់បុត្រព្រះបេស្តា

បង្គាប់ឲ្យខ្ញុំមកមានការ　យ៉ាងណាសូមទ្រង់មេត្តាប្រោស ៗ
អសុរាបិតាថាកូនស្រី　ត្រូតអីបីតាគិតសន្តោស
នាងតាមឪពុកកុំឲ្យទោស　បូលនាងសន្តោសសេចក្តីមើល ៗ
បិតាប្រកែកថាមិនឲ្យ　គេបេះតែបូលយកងងើល
កូនស្រីកុំថាបិតាព្រើល　ងងើលងងិតគិតមិនយល់ ៗ
ឥឡូវគេបោះបូកបំណាំ　ហួសប្រាំមួយឆ្នាំកូនទិមិល
លើសដប់ខែហើយមិនឃើញផល់　តើស្រស់ទិមិលថាដូចម្តេច ៗ
ចន្ទ័បទុមស្រីនាងទូលថា　ដល់ព្រះបិតាមួយរំពេច
ដោយពាក្យសច្ចៈគ្មានកលកិច្ច　ទើបនាងសម្រេចដល់បិតា ៗ
សូមទានឥតទោសលោកឪពុក　ដែលលោកដាក់ទុកកូនឯណា
លើកឲ្យទៅក្រុងអសុរា　ប្រុងរៀបចំការក្នុងថ្ងៃនឹង ៗ
កូនសូមដំរាបឲ្យបានជាក់　ជ្រាបដល់ក្រុងយក្សជាតំណឹង
ការអ្នកឯណាខ្ញុំចង់ដឹង　ដែលប្រឹងចូលមកប្រែនត្រៀបត្រា ៗ
បំណែកខាងខ្ញុំជាកូនស្រី　ទ្រង់ឲ្យមានប្តីយូរហើយណា
កូនណាមួយទៀតដែលរៀបការ　សូមព្រះបិតាប្រាប់កូនផង ៗ
កាលនោះអសុរីជាបិតា　បន្ទ័បទុមាស្វរឡោះហោង
រកពាក្យត្រង់ណានឹងឆ្លើយឆ្លង　តទឹងនាងផងបាត់សូន្យឈឹង ៗ
បំណែកអ្នកផ្ទូវនឹងអ្នកមហា　ត្កុនាងចរចាប្រាប់ដំណឹង

នាំគ្នាបញ្ឈរក្អែកធ្វើស្ទឹង
ឆ្លើយថាស្ដេចពឹងខ្ញុំមកទេ ៗ
បន្ទន់បន្ទុមស្រីស្ដីសារស័ព្ទ
សំដីចំណាប់ចេះការក្ដើ
ទូលព្រះបិតាដោយរិះរេ
ក្រែងពុំត្រូវទេព្រះបិតា ៗ
ព្រះអង្គមានបុត្រតែមួយផង
គឺខ្ញុំឯងហោងនេះទេណា
ឥឡូវបានកូនមករៀបការ
កូននៅឯណាស្ដេចពុំឃើញ ៗ
ចំណែកស្វាមីគឺប្ដីខ្ញុំ
ហួសប្រាំមួយឆ្នាំមិនអញ្ជើញ
លើសដប់ខែទៀតក៏មិនឃើញ
មិនទាន់អញ្ជើញមកដល់ឡើយ ៗ
ប្រហែលបិតាគិតយកខ្ញុំ
ផ្សំផ្គុំនឹងគេទេដឹងអើយ
ខ្ញុំសួររកកូនពុំប្រាប់ឡើយ
ឱបិតាអើយគិតដូចម្ដេច ៗ
មហាមេឃបិតានឹងមហាផាល
ឮនាងផ្ចាញ់ផ្ចាលដោយពាក្យពេចន៍
គិតថាការនេះមិនសម្រេច
តើយើងគិតម្ដេចវិញ្ញាមាត្យ ៗ
បន្ទន់បន្ទុមស្រីមិនយល់ព្រម
នឹងល្អមគិតការតទៅទៀត
បើដូច្នេះតើត្រូវវិញ្ញាមាត្យ
យើងគិតធ្វើធ្វៀតដូចម្ដេចវិញ ៗ
វិញ្ញាមាត្យថាអើក្រើមហាមេឃ
យើងឃាត់អ្នកពេកពីមុនមិញ
ឥឡូវបើនាងមិនស្រឡាញ់
អញរកកូនណាឲ្យក្ដើបាន ៗ
ចំណែកខាងអញឥតបង្ខំ
នឹងរាយនឹងផ្ដុំស្រីកល្យាណ
ឲ្យមានប្ដីហើយតែម្ដេចបាន
យើងខានបន្ទន់ទៅក្រើរើយ ៗ
កាលនោះមហាផាលអសុរបុត្រ
ខឹងញ័ររន្ធត់ពេកជាត្រើយ

សំយ៉ុងភក្ត្រផ្ទប់មិនងើបងើយ ខ្មាស់អើយសែនខ្មាស់ឥតឧបមា ៗ
ទើបក្រោកចេញពីទីប្រជុំ ដោយកើតទុក្ខធំក្នុងកាយា
ស្រែកប្រាប់ប្រកាសពោលពាក្យថា ចន្ទ៌បទុមាយកឲ្យបាន ៗ
រឿងនេះឈប់ស្ទះមិនពណ៌នា សូមថ្លែងចរចាដោយដើមដាន
ពីក្សត្រពីរពង្សទ្រង់យាងបាន ចរចូលក្នុងស្ថានក្រុងយក្សា ៗ
យាត្រាចូលក្នុងទីវាំងជ័យ ដោយឥតខ្លាចភ័យយក្សឯណា
ចូលដល់ទៅក្រុងអសុរា ជាព្រះបិតារបស់ខ្លួន ៗ
កាលនោះក្សត្រិយ៍ស្រីចន្ទ្រា ចន្ទ៌បទុមាស្រស់ស្រីសួន
ក្រឡេកឃើញប្តីហើយនឹងបុទ្ម ស្រីនួនស្ទុះទៅប្រវាឱប ៗ
ទើបស្តេចទ្រង់លើកព្រះហត្ថា ទាំងពីរហើយណាទ្រង់ក្រសោប
បង់បាត់ស្មារតីដូចគេគប់ ប្រវាឱបហើយសោយសោកា ៗ
ជាទីកំសត់ស្រស់ពន្លក បងស្ទុះស្ទួនមករកពំនារ
បំណាច់បំណងចង់ប្រាថ្នា ឥឡូវជួបគ្នាហើយស្រីពៅ ៗ
កាលនោះនាងចន្ទ៌បទុមស្រី នឹកព្រះស្វាមីពេកឆោមឆ្នៅ
ក្នុងចិត្តអន់អួលរំជួលក្តៅ នឹងយក្សឃោរឃៅពេញត្រៀបត្រា ៗ
ទើបនាងក្រាបទូលព្រះស្វាមី ឲ្យជាប់សេចក្តីសព្វកិច្ចការ
បំពោះព្រះភក្ត្រវរបិតា កុំឲ្យនិន្ទាដល់នាងឡើយ ៗ
ពួកយក្សតណ្តឹងគិតរៀបការ ខ្ញុំម្ចាស់នេះណាទឹងគេហើយ

បិតាប្រកែកថាមិនឲ្យ ខ្លាចក្រែងថ្ងៃក្រោយមានរឿងធំៗ
មហាមេឃអសុរាបេះតែមក បេះតែលៃលកគិតរៀបចំ
ឥឡូវរឿងនេះបែកការធំ កំពុងជំនុំជំរះគ្នា ។
កាលអឺយកាលនោះអង្គក្សត្រថ្ងៃ ឯកាចក្រឹមានបេស្ដា
ព្រះក្សត្រិយ៍ស្ដីថា បន្ទូលប្រាប់ថាសព្វសេចក្ដី ។
ស្ដេចត្រាស់តម្រាសតបទឹងយក ឥតមានទើសទាក់ដោយសំដី
ជាចំណែកខាងអសុរី ដែលចូលមកស្ដីប្រពន្ធខ្ញុំ ។
បិតាប្រកែកថាមិនឲ្យ ចូលមកញយៗគិតរៀបចំ
ចន្ទបទុមនេះប្រពន្ធខ្ញុំ មករៀបចំការដួបម្ដេចបាន ។
បេះធ្វើបំពានអាងអំណាច អាងខ្លួនមិនខ្លាចចិត្តសាម៉ាន
ធ្វើម្ដេចធ្វើទៅឲ្យតែបាន បំពុះបំពានអាងបេស្ដា ។
កាលអឺយកាលនោះក្រុងមហាមេឃ ដួងចិត្តក្ដៅពេកក្រេវក្រោធា
ថាយើអាដែងជាតិមនុស្ស ចិត្តវាមោហាព្រហើនក្រៃ ។
វាហ៊ានពោលពាក្យថាឲ្យអញ អានេះវាមិនស្គាល់គេដដៃ
អាចោរមនុស្សចិត្តចង្រៃ មុខស្លាប់នឹងដៃអញមិនខាន ។
ថាហើយទន្ទ្រាំដែនពសុធា យក្សក្រេវក្រោធាពន់ប្រមាណ
ស្រែកហៅរេហ៍ពលចេញក្រៅស្ថាន ពួកយក្សប៉ុន្មានគិតចម្បាំង ។
ពួកយក្សហ៊ឹកហ៊ាក់ប្រឹងក្រៃពេក អនន្តអនេករៀបតតាំង

ដោយទឹកឈឺចិត្តដេរដេះខ្ទាំង ប្រណាំងរិទ្ធីព្រះចេស្តា ៗ
កាលនោះឯអង្គព្រះចមក្រ ជាព្រះរៀមរកអង្គឯកា
គង់ជិតស្រីចន្ទ៍បទុមា កក្រ្តដូបចន្រ្ទាមូលក្រឡង់ ៗ
ព្រមទាំងព្រះបាទអនុជា ជាកនិដ្ឋាព្រះចមពង្ស
ប្រថាប់ព្រះទែនទាំងបីអង្គ គង់គាល់វិរុឡ្ហមាត្យពង្សក្សត្រា ៗ
ទ្រង់ទតព្រះនេត្រឃើញពលយក្ស ច្រើនរាន់ត្បួរអនេកា
ទើបស្តេចមានព្រះបន្ទូលថា ហៃកូនទ្វេហាទាំងពីរប្រាណ ៗ
ហេតុនេះយើងគិតធ្វើដូចម្តេច មហាមេឃអសុភចិត្តក្លាហាន
ប្រមូលពួកពលមីរមូលបាន ពាសពេញក្នុងស្ថានព្រះសេមា ៗ
ដូចនេះតើកូនគិតដូចម្តេច កុំឲ្យថោកទាបព្រះចេស្តា
កុំឲ្យថោកទាបដល់សេមា ថោកដល់មាតាបិតាផង ៗ
ដូចនេះបិតាប្រគល់ឲ្យ តទៅខាងក្រោយសោយរាជ្យផ្គង
ជំនួសបិតាអញឯងហោង ស្នងត្រងនគរលើកនឯង ៗ
កូនប្អូនឪពុកឲ្យអំណាច ឡើងធ្វើឧបរាជ្យប្រាកដស្តួន
ប្រគល់រេហ៍ពលទីកន្ទ្វង ស្រេចទឹងកូនឯងទាំងទ្វេហា ៗ
ចន្ទ៍បទុមាជាបុត្រី តាំងទីមហេសីអង្គឯកា
ជាធំលើសអស់ស្នំស្រីង្គារ ក្នុងព្រះសេមាពេជ្របុរី ៗ
ឥឡូវហេតុនេះកើតចម្បាំង ប្រណាំងដណ្តើមបទុមស្រី

តើគិតដូចម្ដេចបុត្រពិសី    ខ្មាស់អសុរីក្រុងមហាមេឃ ៗ
កាលអើយកាលនោះអង្គឯកា    ព្ធព្រះបិតាព្រួយខ្វាំងពេក
ដោយឃើញពលយក្សច្រើនអនេក    ឥតមានប្រកែកដល់តិចឡើយ ៗ
ប្រាប់អនុជាឲ្យរៀបពល    បញ្ចប់ខ្វាយខ្វល់មកដល់ហើយ
ចម្បាំងពេលនេះពុំលែងឡើយ    ពលពាលមុខក្រោយពេញត្រៀបត្រា
រៀបស្រេចចូលទូលអង្គចមក្សត្រ    បពិត្រចក្រពត្រចមដេជ្ជា
បំណែកខាងពួកពលសេនា    រួចស្រេចហើយណាព្រះរៀមថ្លៃ ៗ
ព្រះបាទឯកាចមចក្រី    ព្ធអនុជស្ដីត្រេកអរក្រៃ
ចុះចាកប្រាសាទរំពេចខ្មី    បង្គាប់សេនីយ៍ទឹងសេនា ៗ
ឲ្យរៀបប្រុងប្រៀបរៀបគ្រប់ប្រាណ    សេនាប៉ុន្មានសង្គ្រាមជ័យ
យើងលើកទៅតទឹងអសុរី    ឲ្យដឹងដេដដៃក្នុងគ្រាទឹង ៗ
កាលនោះមហាមេឃអង្គអសុរី    គ្រាំក្រោធពេកក្រៃដោយកំហឹង
មាហាដាលអសុរាក៏ក្រោធខឹង    គិតថាពេលទឹងឲ្យអស់រិទ្ធ៍ ៗ
បើសិនអញចាញ់អាមនុស្ស    ស្លាប់ទៅកាលណាអញលែងគិត
រស់នៅធ្វើអ្វីខ្មាស់រាពិត    ឲ្យអស់ជីវិតល្អជាជាង ៗ
មហាមេឃអសុរីធ្មុលធេវខ្វាំង    ប្រកាសចម្បាំងព្ធសូរសៀង
មហាដាលបុត្រាក៏ក្អេងក្អាង    ព្ធបង្រាស់ដល់នាងចន្ទ៍បទុម ៗ
កាលអ៊ឹយកាលនោះវរក្សត្រិយ៍    ព្ធពាក្យអសុរីពុំគួរសម

ទុកជាទុក្ខមុខក្រៀមក្រំ　　បារម្ភអំពីសង្គ្រាមភ័យ ។
ក្រែងទប់ទល់រិទ្ធិយក្សពុំបាន　　អសុរាខ្លាហានឥតឧបម័យ
ក្រែងព្រះបរមក្សត្រិយ៍ថយតេជដៃ　　ក្រុងអសុរីយកនាងបាន ។
តាំងពីក្សត្រាយាងមកដល់　　ទីស្ថានមណ្ឌលព្រះរាជស្ថាន
ពុំដែលបានផ្ទុំសុខសម្រាន្ត　　ជាមួយកល្យាណទឹមនួនស្រី ។
កើតកោលាហលខ្វល់វិករ　　ក្នុងព្រះនគររាជបុរី
ពុំបានរួមស្ថានទឹងមហេសី　　ដោយព្រះបក្រិមាះភ័យធំ ។
ព្រះបាទឯកាបក្ករិទ្ធិ　　ព្រះទ័យទ្រង់គិតក្តីបារម្ភ
ស្រុកកើតសឹកសាមសង្គ្រាមធំ　　បង្គុំគិតតែគ្រឿងបម្រុង ។
កាលនោះសម្តេចអនុជា　　លើកពលយោធាចេញតតាំង
នឹងក្រុងអសុររិទ្ធិខ្លាំង　　ថ្វីងដោយកម្លាំងរិទ្ធិពលប្រាណ ។
ក្រុងយក្សថ្វីងជាគំនរភ្លើង　　ចេវធាបចេះឡើងក្នុងរាជស្ថាន
ព្រះបាទឯកាក្សត្រិយ៍ថ្កើងថ្កាន　　យកកន្សែងបានបក់ឡើងខ្មី ។
កើតជាទឹកភ្លៀងលត់ភ្លើងយក្ស　　ត្រជាក់សាយសព្វគតផែនដី
គ្មានក្តៅដល់ពួកពលសេនីយ៍　　នឹងពីរក្សត្រថ្លៃដល់តិចឡើយ ។
យក្សថ្វីងពពកភ្លើងឲ្យលិត　　មេឃខ្មៅជុំជិតសព្វទិសហើយ
ចូលត្រកងបីស្ត្រីត្រាណត្រើយ　　យកបានមកហើយពីរាជស្ថាន ។
ពហោះសំដៅទៅនគរ　　ឈ្មោះកោះគិរីរាជ្យថ្កើងថ្កាន

ព្រះបាទឯការាជមក្សត្រក្បាន្ត  ចាប់កន្សែងបានបក់ឡើងខ្ទី ៗ
កើតជាពពោយបក់ផាយផាត់  រសាត់ពពកអន្ធអប្រិយ៍
ទ្រង់ទតព្រះនេត្រឃើញអសុរី  ពបទុមស្រីហោះលឿនក្រៃ ៗ
ស្តេចលើកព្រះហស្តខាងស្តាំឡើង  ចង្អុលប្រាប់ព្រះអនុជថ្លៃ
ប្អូនប្រុសមើលនយក្សចង្រៃ  ពបទុមស្រីហោះទៅហើយ ៗ
ទើបព្រះអនុជមានបុណ្យច្រើន  ចាប់យកខ្សែឡើងគ្រវែងផ្ញើយ
ដេញចង្ក្រុងយក្សជាប់ពីក្រោយ  ទាញបានមកហើយបំពោះក្រួ ៗ
បង់ពាំងវេហ៍ពលយក្សប៉ុន្មាន  រួបរិតអង្គប្រាណទាញកន្ត្រាក់
ជម្បូងកាយឯងឥតក្រែងយក្ស  ភិតភ័យញាវិញាក់រាក់ស្មារតី ៗ
យក្សស្រែកអង្វរក្សត្រទ្វេហា  បពិត្រដេជ្ញាបមបក្រី
ព្រះអង្គជាម្ចាស់លើសិរសើ  សូមព្រះនរបតីទុកជីពជន្ម ៗ
សូមចុះសូមពាញ់ព្រះបារមី  ថ្វាយទឹកថ្វាយដីស្រុកជម្ពូទ៌
ប្រទេសនិគមឃុំខេត្តខណ្ឌ  ក្រុងធំសោភ័ណកោះគីរី ៗ
មហាមេឃបិតាអង្វរក្សត្រ  ពាំងពីរចក្ខុវត្តលង្ឃូលី
ឯអសុរីបុត្រផុតជីវិ  ក្ស័យនៅក្នុងទីនោះឯងណា ៗ
ខ្សែពីរសន្ធបជាបែបខ្វី  តទៅខ្សែបីស្តីអស្ចារ្យ
ពីអសុរីបុត្រផុតសំខារ  កើតឡើងកាលណាតបទៅវិញ ៗ

ពលឯក ទីពីរ ចប់

មានតខ្សែ៣ទៀត

រោងពុម្ពកុមារពាណិជ្ជ

លេខ ១៦ មហាវិថីព្រះស៊ីសុវត្ថិ

ភ្នំពេញ